ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ០៩ អយក.ឋ3

នាយកដ្ឋានពត៌មាននិងកិច្ចការអាស៊ាន
លេខ...19...
ថ្ងៃទី...12...ខែមករាឆ្នាំ២០12
ម៉ោង...10...

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែមករា ឆ្នាំ ២០១២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**ជម្រាបមក**

**លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និង កីឡារាជធានីភ្នំពេញ និងខេត្ត**

**កម្មវត្ថុ** : ការបើកវគ្គបំប៉នគ្រូបង្រៀនកម្រិតមូលដ្ឋាន ជំនាន់ទី ៦

**យោង** : លិខិតលេខ ១៦៦០ សជណ.អវ ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥

តតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក លោកស្រីប្រធានថា ក្រសួងអប់រំ យុវជន និងកីឡា មានគម្រោងបើកវគ្គបំប៉នគ្រូបង្រៀនកម្រិតមូលដ្ឋានជំនាន់ទី៦ ចំនួន ១៥០០នាក់ រយៈពេលបីខែ ចាប់ពីមហាវិស្សមកាលឆ្នាំសិក្សា២០១១-២០១២ នេះតទៅ នៅតាម មជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៦ ដោយចែកជាពីរវេន ÷

- វេនទី ១ ចាប់ពីថ្ងៃទី ០១ ខែ សីហា ដល់ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១២
- វេនទី ២ ចាប់ពីថ្ងៃទី ០១ ខែ សីហា ដល់ថ្ងៃ ទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៣

សូមលោក លោកស្រី រៀបចំផ្សព្វផ្សាយ និង ជ្រើសរើសគ្រូបឋមសិក្សា ឬ មត្តេយ្យសិក្សា ដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិនៅតាម រាជធានីភ្នំពេញ-ខេត្ត របស់លោក លោកស្រីតាមការណែនាំដូចខាងក្រោម ÷

**I-លក្ខខណ្ឌជ្រើសរើស :** ជ្រើសរើសក្នុងចំណោមគ្រូបឋមសិក្សា ឬ មត្តេយ្យសិក្សាទាំងពីរភេទដែលមានសញ្ញាប័ត្រមធ្យសិក្សាទុតិយភូមិ និងមានអាយុ យ៉ាងច្រើន ៥៥ ឆ្នាំ គិតដល់ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១២ ហើយដែល ÷

១-បានតែងតាំងស៊ុបក្នុងក្របខ័ណ្ឌ

២-មានអតីតភាពច្រើនជាងគេ ក្នុងករណីអតីតភាពស្មើគ្នាត្រូវផ្តល់អាទិភាពទៅនារី បន្ទាប់មកទៀតអ្នកមានអាយុច្រើនជាង។

II- បំណែងចែកសិក្ខាកាមតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ

| ល.រ | ខេត្ត-ក្រុង | ភាសាខ្មែរ សីល-ពលរដ្ឋ | ខ្មែរ គេហវិទ្យា | ប្រវត្តិវិទ្យា ភូមិវិទ្យា | គណិត រូបវិទ្យា | រូបវិទ្យា គីមីវិទ្យា | ជីវវិទ្យា ផែនដីវិទ្យា | សរុប | ទីកន្លែង បំប៉ន |
|---|---|---|---|---|---|---|---|---|---|
| ១ | រាជធានីភ្នំពេញ | ១៥ | ១៧ | ១៦ | ២០ | ១៧ | ១២ | ៩៧ | មជ្ឈមណ្ឌល |
| ២ | ស្ទឹងត្រែង | ៥ | ៥ | ៥ | ៤ | ៤ | ៣ | ២៦ | គរុកោសល្យ |
| ៣ | ព្រះវិហារ | ៧ | ៥ | ៥ | ៥ | ៤ | ៤ | ៣០ | ភូមិភាគ |
| ៤ | កោះកុង | ៦ | ៦ | ៥ | ៦ | ៥ | ៣ | ៣១ | រាជធានី |
| ៥ | រតនគិរី | ៦ | ៥ | ៤ | ៦ | ៤ | ៣ | ២៨ | ភ្នំពេញ |
| ៦ | មណ្ឌលគិរី | ៤ | ៤ | ៤ | ៤ | ៣ | ២ | ២១ | |
| ៧ | ក្រសួងអយក | ២៤ | ៩ | ៩ | ១៣ | ៣ | ២ | ៦០ | |
| | **សរុប** | **៦៧** | **៥១** | **៤៨** | **៥៨** | **៤០** | **២៩** | **២៩៣** | |
| | **ចំនួនថ្នាក់** | **២** | **២** | **២** | **២** | **២** | **១** | **១១** | |
| ៨ | កណ្ដាល | ២២ | ១៥ | ១៥ | ២៩ | ១៤ | ១៣ | ១០៨ | មជ្ឈ.គរុ |
| ៩ | កំពង់ឆ្នាំង | ១៥ | ៨ | ៨ | ១៣ | ៧ | ៦ | ៥៧ | ភូមិភាគ |
| ១០ | កំពង់ស្ពឺ | ១៥ | ៩ | ៨ | ១៥ | ៨ | ៧ | ៦២ | ខេត្តកណ្ដាល |
| **សរុប** | | **៥២** | **៣២** | **៣១** | **៥៧** | **២៩** | **២៦** | **២២៧** | |
| | **ចំនួនថ្នាក់** | **២** | **១** | **១** | **២** | **១** | **១** | **៨** | |
| ១១ | បាត់ដំបង | ១៧ | ១៦ | ១៤ | ២៧ | ១៥ | ១៥ | ១០៤ | មជ្ឈមណ្ឌល |
| ១២ | ពោធិសាត់ | ១១ | ១០ | ៩ | ១៣ | ៨ | ៨ | ៥៩ | គរុកោសល្យ |
| ១៣ | បន្ទាយមានជ័យ | ១១ | ១០ | ៨ | ១៣ | ៨ | ៨ | ៥៨ | ភូមិភាគ |
| ១៤ | សៀមរាប | ១១ | ១០ | ៨ | ១៣ | ៨ | ៨ | ៥៨ | ខេត្តបាត់ដំបង |
| ១៥ | ឧត្តរមានជ័យ | ៥ | ៥ | ៤ | ៤ | ៣ | ៣ | ២៤ | |
| ១៦ | ប៉ៃលិន | ៥ | ៥ | ៤ | ៤ | ៣ | ៣ | ២៤ | |
| **សរុប** | | **៦០** | **៥៦** | **៤៧** | **៧៤** | **៤៥** | **៤៥** | **៣២៧** | |
| | **ចំនួនថ្នាក់** | **២** | **២** | **២** | **៣** | **២** | **២** | **១៣** | |
| ១៧ | កំពង់ចាម | ២២ | ១៤ | ១៥ | ២៥ | ១៤ | ១៣ | ១០៣ | មជ្ឈ.គរុ |
| ១៨ | កំពង់ធំ | ២០ | ១០ | ១២ | ២០ | ១១ | ១០ | ៨៣ | ភូមិភាគ |
| ១៩ | ក្រចេះ | ១៧ | ៧ | ៧ | ១០ | ៦ | ៦ | ៥៣ | ខេត្តកំពង់ចាម |
| **សរុប** | | **៥៩** | **៣១** | **៣៤** | **៥៥** | **៣១** | **២៩** | **២៣៩** | |
| | **ចំនួនថ្នាក់** | **២** | **១** | **១** | **២** | **១** | **១** | **៨** | |
| ២០ | ព្រៃវែង | ១៦ | ១៤ | ១៤ | ១៩ | ១៣ | ១២ | ៨៨ | មជ្ឈ.គរុ |
| ២១ | ស្វាយរៀង | ១៣ | ១៣ | ១១ | ១១ | ១០ | ១០ | ៦៨ | ភូមិភាគ |
| **សរុប** | | **២៩** | **២៧** | **២៥** | **៣០** | **២៣** | **២២** | **១៥៦** | ខេត្តព្រៃវែង |
| | **ចំនួនថ្នាក់** | **១** | **១** | **១** | **១** | **១** | **១** | **៦** | |
| ២២ | តាកែវ | ២២ | ១៧ | ១៨ | ២០ | ១២ | ១២ | ១០១ | |
| ២៣ | កំពត | ១៤ | ១៤ | ១៤ | ២១ | ៨ | ៨ | ៧៩ | មជ្ឈ.គរុ |
| ២៤ | ព្រះសីហនុ | ៨ | ៨ | ៨ | ១០ | ៦ | ៥ | ៤៥ | ភូមិភាគ |
| ២៥ | កែប | ៨ | ៧ | ៥ | ៦ | ៤ | ៣ | ៣៣ | ខេត្តតាកែវ |
| **សរុប** | | **៥២** | **៤៦** | **៤៥** | **៥៧** | **៣០** | **២៨** | **២៥៨** | |
| | **ចំនួនថ្នាក់** | **២** | **២** | **២** | **២** | **១** | **១** | **១០** | |
| **សរុបរួម** | | **៣១៩** | **២៤៣** | **២៣០** | **៣៣១** | **១៩៨** | **១៧៩** | **១៥០០** | |
| **សរុបចំនួនថ្នាក់** | | **១១** | **៩** | **៩** | **១២** | **៨** | **៧** | **៥៦** | |

## III-ការជ្រើសរើស

ក-មន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ-ខេត្តត្រូវ ÷

- បង្កើតគណៈកម្មការមួយដែលមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| ១-ប្រធានមន្ទីរ អប់រំ យុវជន និង កីឡារាជធានីភ្នំពេញ-ខេត្ត | ប្រធាន |
| ២-អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ-ខេត្ត ទទួលបន្ទុកបុគ្គលិក-បណ្តុះបណ្តាល | អនុប្រធាន |
| ៣-អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ-ខេត្ត ទទួលបន្ទុកមធ្យមសិក្សា | អនុប្រធាន |
| ៤-អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ-ខេត្ត ទទួលបន្ទុកបឋមសិក្សា | អនុប្រធាន |
| ៥-ប្រធានការិយាល័យបុគ្គលិក -បណ្តុះបណ្តាល | សមាជិក |
| ៦-ប្រធានការិយាល័យមធ្យមសិក្សា | សមាជិក |
| ៧-ប្រធានការិយាល័យបឋមសិក្សា | សមាជិក |
| ៨-ប្រធានការិយាល័យអប់រំ ក្រុង-ខ័ណ្ឌ-ស្រុក | សមាជិក |

-គណៈកម្មការខាងលើនេះមានភារកិច្ច ÷

+ បំផុស និងផ្សព្វផ្សាយឱ្យគ្រូបឋមសិក្សា ឬ មត្តេយ្យសិក្សាដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បានបំពេញសលាកបត្រឯកត្តជនគ្រប់គ្នា ។

+ ជ្រើសរើស និងកំណត់មុខសញ្ញាឱ្យបានសមស្របទៅតាមល័ក្ខខ័ណ្ឌ តាមមុខវិជ្ជាឯកទេស តាមចំនួនកំណត់ ។

+ ណែនាំបេក្ខជនដែលត្រូវបានជ្រើសរើសឱ្យដាក់ពាក្យសុំចុះឈ្មោះចូលរៀនបានទាន់ពេលវេលា ។

+ ពិនិត្យសំណុំលិខិតរបស់សិក្ខាកាមឱ្យបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌជ្រើសរើស ។

+រៀបចំសំណុំលិខិតសុំចុះឈ្មោះចូលរៀនរបស់សិក្ខាកាម និងបញ្ជីរាយនាមសិក្ខាកាមតាមមុខវិជ្ជា "គំរូជូនភ្ជាប់" បញ្ជូនទៅក្រសួងអប់រំយុវជន និង កីឡា (នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ) ចំនួន ១ ច្បាប់ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន ១ច្បាប់ ឱ្យបានមុនថ្ងៃទី១៥ ខែ ឧសភា ឆ្នាំ ២០១២ ។

ខ- មជ្ឈមណ្ឌលគរុកោសល្យភូមិភាគត្រូវ ÷

- ទទួលសំណុំលិខិត និង បញ្ជីរាយនាមសិក្ខាកាមក្នុងភូមិភាគរបស់ខ្លួន
- រៀបចំបញ្ជីរាយនាមសិក្ខាកាមតាមមុខវិជ្ជាឯកទេស និងតាមរាជធានីភ្នំពេញ-ខេត្ត "គំរូជូនភ្ជាប់" ដើម្បីសុំការយល់ព្រមពីក្រសួង ដោយមានការឯកភាព ពីមន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ-ខេត្ត បន្ទាប់ពីវគ្គបំប៉នដំណើរការបាន ១សប្តាហ៍ ។

## IV - សំណុំលិខិតរបស់បេក្ខជន

- ពាក្យសុំចុះឈ្មោះចូលរៀន " គំរូជូនភ្ជាប់ " ...................................................................................... ២ ច្បាប់
- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណេះទូទៅ ឬ វិញ្ញាបនបត្របណ្តោះអាសន្ន ឬ សញ្ញាបត្រសមមូល
  ( ក្នុងករណីថតចម្លងត្រូវបញ្ជាក់ និងប្រថាប់ត្រាអាជ្ញាធរ រាជធានីភ្នំពេញ-ខេត្ត) ..................................១ ច្បាប់
- ជីវប្រវត្តិសង្ខេប " គំរូជូនភ្ជាប់." ......................................................................................................២ ច្បាប់
- សលាកបត្រឯកត្តជនមានបិទរូបថតថ្មីទំហំ ៤ x ៦ " គំរូជូនភ្ជាប់ " ....................................................... ២ ច្បាប់

- កិច្ចសន្យា "គំរូជូនភ្ជាប់"......"....................................................................................................................២ ច្បាប់

- វិញ្ញាបនបត្ររដ្ឋបាលបញ្ជាក់ដោយមន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ-ខេត្ត" គំរូជូនភ្ជាប់ "..........២ ច្បាប់

- រូបថតថ្មីថតចំពីមុខ គ្មានពាក់មួក គ្មានពាក់វ៉ែនតា ទំហំ (៤ x ៦)......................................................២ច្បាប់ ។

កំណត់សម្គាល់ :

- ក្រសួងអប់រំ យុវជន និង កីឡា មិនទទួលពិនិត្យសំណុំលិខិតរបស់បេក្ខជនទាំងឡាយណាដែលមិនគ្រប់គ្រាន់ ក្លែងបន្លំ ឬ មិនត្រឹមត្រូវតាមល័ក្ខខ័ណ្ឌខាងលើ

- មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ-ខេត្ត ត្រូវទទួលខុសត្រូវចំពោះមុខបេក្ខជន និងក្រសួង ក្នុងករណីមានបញ្ហាខាងលើនេះកើតឡើង ។

- ក្រោយចប់វគ្គបំប៉ន សាមីខ្លួនត្រូវទៅបម្រើការងារនៅអង្គភាពដើមវិញតាមការចាត់តាំងរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងខេត្ត ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីប្រធានអនុវត្តការងារនេះឱ្យទទួលបានលទ្ធផលល្អប្រសើរ ។

សូមលោក លោកស្រីប្រធានទទួលនូវការរាប់អានពីខ្ញុំ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ណាត ប៊ុនរឿន

ចម្លងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលារាជធានីភ្នំពេញ និងគ្រប់សាលាខេត្ត

  " ដើម្បីសូមជ្រាបជាព័តិមាន"
- អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា

  " ដើម្បីជាព័តិមាន"
- មជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង ៦

  " ដើម្បីត្រៀមលក្ខណៈអនុវត្ត "
- កាលប្បវត្តិ
- ឯកសារៈនាយកដ្ឋានបណ្ដុះបណ្ដាល និង វិក្រឹតការ